ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ២០១ ព្រទ-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោកប្រធានតុលាការខេត្ត-ក្រុង**
**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីគោលការណ៍បង្ក្រាបបទល្មើសមួយចំនួន ។

**យោង:** លិខិតណែនាំលេខ ៩៧៨-ព្ររ-៣-២-៩៧ ចុះថ្ងៃទី១០-០៩-៩៧ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានធ្វើលិខិតណែនាំដូចមានយោងខាងលើដើម្បីចាត់វិធានការបង្ក្រាបអំពើល្មើសមួយចំនួន ដែលកំពុងតែធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសាធារណៈយ៉ាងធ្ងន់ធ្ងររួចមកហើយ ប៉ុន្តែរហូតមកដល់ថ្ងៃនេះក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អំពើល្មើសទាំងនោះនៅតែគំរាមគំហែងដល់សន្តិសុខសាធារណៈដដែលពុំទាន់បានចុះថយនៅឡើយ ។

ផ្អែកតាមសភាពការណ៍បច្ចុប្បន្ន អំពើល្មើសដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសាធារណៈយ៉ាងធ្ងន់ធ្ងរគឺបង្ករឡើងដោយក្រុមជនទុច្ចរឹតដែលបានប្រព្រឹត្តចាប់មនុស្សជំរិតយកប្រាក់ គំរាមគំហែងទារប្រាក់តាមទូរស័ព្ទ ឬតាមសំបុត្រព្រមទាំងអំពើប្លន់ប្រដាប់អាវុធ ដែលបានធ្វើឱ្យប្រជារាស្ត្រស្លូតត្រង់ព្រមទាំងអ្នកវិនិយោគទុនបរទេសមានការភ័យខ្លាចយ៉ាងខ្លាំងសឹងមិនហានមករកស៊ីនៅប្រទេសយើង ។ ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការបំបាត់ភាពភ័យខ្លាចទាំងនេះជូនប្រទេសជាតិយើង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌សូមធ្វើការណែនាំដល់ចៅក្រមទាំងអស់ នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវតែអនុវត្តច្បាប់ឱ្យបានតឹងរឹងជាទីបំផុត ចំពោះប្រភេទជនល្មើសខាងលើនេះដូចតទៅ៖

១-ដាច់ខាតមិនត្រូវឱ្យជនល្មើសនៅក្រៅឃុំទោះបីមានអន្តរាគមន៍ឬមានប្រាក់ធានាយ៉ាងណាក៏ដោយ

២-ត្រូវផ្តន្ទាទោសជាអតិបរមាចំពោះជនល្មើស

៣-មិនត្រូវឲ្យជនល្មើសបានរួចខ្លួនដោយប្រការណាមួយឡើយ ជាពិសេសមិនត្រូវឲ្យមានការភន្ត័ច្រឡំពីអ្នករងគ្រោះទៅជាជនល្មើស ហើយពីជនល្មើសទៅជាអ្នករងគ្រោះវិញទេ ។

៤-អនុវត្តសេចក្តីណែនាំលេខ ៩៧៨.ព្ររ.៣.២-៩៧ ចុះថ្ងៃទី១០-០៩-៩៧ របស់ក្រសួងយុត្តិធម៌ឲ្យបានតឹងរឹង និងប្រសិទ្ធិភាពខ្ពស់បន្តទៀត ។

សេចក្តីណែនាំនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វីធុន**

ចម្លងជូន
-តុលាការកំពូល និងមហាអយ្យការ
-សាលាឧទ្ធរណ៍ និងមហាអយ្យការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ដើម្បីជ្រាប